**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៦. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួល
## សញ្ញាកងវិស្វកម្ម នៃកងយោធពលខេមរភូមិន្ទ
## នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែ មករា ឆ្នាំ១៩៩៧

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួលសញ្ញាកងវិស្វកម្មនៅត្រង់ចំណុច១៦ មាត្រា៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទទៅជាសញ្ញាវិស្វកម្មនៃកងយោធពលខេមរភូមិន្ទដូចខាងក្រោម ៖

**សញ្ញាវិស្វកម្ម**

ក-រូបភាព: និមិត្តសញ្ញា រូបព្រះពិស្ណុការ មានព្រះហស្ត ៨ (ប្រាំបី) កាន់កងចក្រមានកាំ ៩ (ប្រាំបួន) ច្បូកត្រីសូល៍ ចប ពូថៅ ដង្កាប់ គម្ពីរ កុំប៉ា កែង និងស្លាបព្រាកំបោរបាយអរ គង់នៅលើខឿនអមដោយរចនាបថភ្ញីអង្គរខាងស្តាំនិងគួរស្រូវខាងឆ្វេងរាងរង្វង់ស្វែងក្របី ផ្នែកខាងលើព្រះសិរព្រះពិស្ណុការមានកាំរស្មីពណ្ណរាយ១១ (ដប់មួយ) កាំ ផលិតអំពីលោហធាតុពណ៌មាសសម្រាប់ពាក់នៅលើកអាវលេខ២-៣-៤សងខាង និងប៉ាក់ឬបោះពុម្ពពណ៌លឿងលើហ្វុងពណ៌ខ្មៅសម្រាប់ពាក់នៅកអាវប្រយុទ្ធខាងស្តាំនៃនាយទាហានចាប់ពីថ្នាក់វរសេនីយ៍ចុះដល់ពលទាហានទ័ពជំនាញវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ ។

ខ-ខ្នាត: -មានរាងពងក្រពើ កំពស់៣៥ មម ទទឹង២៥ មម កំរាស់១.៥ មម

-ព្រះពិស្ណុការមានកំពស់២៦ មម ទំហំស្មា៦ មម

-ខឿនមានកំពស់៤ មម បាតក្រោម៩ មម បាតលើ៧ មម

-កាំរស្មីពណ្ណរាយកាំនីមួយៗ ប្រវែង៤ មម និង ៥ មម

-ភ្ញីអង្គរប្រវែង៣០ មម ទំហំ កណ្តាល៣ មម

-ភ្ញីគួរស្រូវប្រវែង៣០ មម ទំហំកណ្តាល៣ មម

-ផ្ទៃហ្វុងពណ៌ខ្មៅ ទំហំ២៧ មមx៣៧ មម កំរាស់១.៥ មម ។

រូបភាពនិងខ្នាតនៃសញ្ញាវិស្វកម្មមានគំរូក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

សញ្ញាកងវិស្វកម្ម ត្រង់ចំណុច ១៦ មាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេរភូមិន្ទ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធ [illegible]

**ស្ដីអំពី**

**រូបភាព អត្ថន័យ របស់និមិត្តសញ្ញាវិស្វកម្ម**

**នៃកងយោធពលខេមរភូមិន្ទ ទាំង ២ សណ្ឋាន ៖**

I. **សណ្ឋានទី ១** «ធ្វើអំពីស្ពាន់» សំរាប់ពាក់នៅករាវលេខ ២-៣-៤ សងខាង «ថ្នាក់វរសេនីយ៍ចុះ» ទំហំ ទទឹង ២៥មម. កំពស់៣៥មម.




II. **សណ្ឋានទី ២** « ប៉ាក់ពណ៌លឿងលើផ្ទៃក្រណាត់ខ្មៅ » សំរាប់ពាក់នៅកអាវប្រយុទ្ធម្ខាងស្ដាំ «ថ្នាក់ វរសេនីយ៍ចុះ» ទំហំផ្ទៃក្រណាត់ខ្មៅ ២៧មម.x ៣៧មម. ទំហំព្រះពិស្ណុការ ទទឹង២៥ មម. កំពស់៣៥ មម.



**អត្ថន័យនៃនិមិត្តសញ្ញា**

១. "**ព្រះពិស្ណុការ**" ជានិមិត្តរូបតំណាងអោយតួនាទី-ភារកិច្ចកងវិស្វកម្ម នៃកងយោធពលខេមរភូមិន្ទ ដែលជាអ្នកចូលរួមកសាងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គម សំណង់ការពារប្រទេស សំណង់ផ្សេងៗនិងចូលរួមវិស័យដទៃទៀតដោយឆន្ទៈមុះមុត អង់អាចក្លាហាន ឧស្សាព្យាយាម តស៊ូអត់ធ្មត់ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ទឹកចិត្តស្មោះត្រង់ភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ ជាកម្លាំងស្នូល និងជាកម្លាំងផ្តាច់ព្រ័ត្ររបស់រាជរដ្ឋាភិបាល ។

២. <u>កាំរស្មីពណ្ណរាយ លើព្រះសិរ តំណាងអោយ</u>.

+ វប្បធម៌ប្រពៃណីល្អស្អាតផូរផង់ ការពុះពាររាល់ឧបសគ្គ និងការធ្វើពលិកម្មគ្រប់បែបយ៉ាង ឆន្ទៈប្រយុទ្ធយ៉ាងអង់អាចក្លាហាន ដើម្បីសំរេចល្អឆ្នើមរាល់ភារកិច្ចថ្នាក់លើប្រគល់អោយ នៅគ្រប់កាលៈទេសៈ ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ រុងរឿង ភ្លឺចិញ្ចាច ល្បី ខ្ចរខ្ចាររបស់កងវិស្វកម្ម នៃកងយោធពលខេមរភូមិន្ទ ។
+ បញ្ញាញាណត្រឹមត្រូវ ភ្លឺស្វាង ប្រកបដោយគតិបណ្ឌិតរបស់កងវិស្វកម្ម ក្នុងតួនាទី ធ្វើសេនាធិការ ជូនថ្នាក់ដឹកនាំ ។

៣. <u>ព្រះហស្តទាំង ៨</u> តំណាងអោយសមត្ថភាព ទេពកោសល្យ និងបណ្តាជំនាញរបស់កងវិស្វកម្មក្នុងកងយោធពលខេមរភូមិន្ទ ។

៤. <u>ឧបករណ៍ សម្ភារៈទ្រង់លើព្រះហស្តទាំង ៨ តំណាងអោយ</u> ៖

* <u>កងចក្រ ៩កាំ តំណាងអោយៈ</u>
  + មធ្យោបាយគ្រឿងចក្រ សម្ភារៈ គ្រឿងបំពាក់ទាំងឡាយរបស់កងវិស្វកម្ម ។
  + ការធានាចម្លង និងធានាចល័ត តភ្ជាប់បណ្តាញផ្លូវគមនាគមន៍ និងការចូលរួមជួយសង្គ្រោះប្រជាពលរដ្ឋជួបគ្រោះមហន្តរាយផ្សេងៗ ។
* <u>ច្បូក(ត្រីសូល៍) តំណាងអោយៈ</u>
  + ការកសាងនិងពុះពារវត្ថុរាំង ផ្ទុះនិងមិនផ្ទុះ ។
  + ម៉ាស៊ីននិងឧបករណ៍ សំរាប់បោសសំអាតគ្រាប់មីន និងក្បាលគ្រាប់មិនទាន់ផ្ទុះ ធានាសុវត្ថិភាពជូនថ្នាក់ដឹកនាំជាតិនិងអន្តរជាតិ និងធានាអោយការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម សង្គមកិច្ច ...។ល។
* <u>ចប ពូថៅ តំណាងអោយៈ</u>
  + ការកសាងខឿនការពារប្រទេសដ៏រឹងមាំ ប្រព័ន្ធលេណដ្ឋាន ទីបញ្ជាការ ឃ្លាំងក្រោមដី ផ្លូវរូង ព្រលានយន្តហោះ កំពង់ផែយោធា ។
* <u>កុំប៉ា កែង និងស្លាបព្រាកំបោរបាយអ តំណាងអោយៈ</u>
  + ការស្ថាបនាសំណង់បេតុង រួមមានៈ សំណង់សិល្បការ្យ ( ថ្នល់-ស្ពាន) សំណង់អគារតូច-ធំ សំណង់ធារាសាស្រ្ត ...ជាដើម ។

+ គុណភាពរឹងមាំ និងសោភ័ណភាពនៃសំណង់ ។

* <u>គម្ពីរ តំណាងអោយៈ</u>

+ ការគោរពច្បាប់របស់រដ្ឋ លក្ខន្តិកៈទូទៅ វិន័យ សីលធម៌ និងបទបញ្ជារបស់កងវិស្វកម្ម នៃកងយោធពលខេមរភូមិន្ទ ។ ស្មោះត្រង់ដាច់ខាតចំពោះជាតិមាតុភូមិ រដ្ឋាភិបាល និងកងយោធពលខេមរភូមិន្ទ ។ ប្រព្រឹត្តតែអំពើល្អ និងជួយប្រជាជន ។

+ ក្បួនតម្រាផ្សេងៗ សំរាប់បណ្ដុះបណ្ដាល កសាងធនធានមនុស្ស និងសំរាប់កសាងកងវិស្វកម្ម រឹងមាំលើគ្រប់វិស័យ ។

+ ក្បួនតម្រាផ្សេងៗ ចែងអំពីលិខិតបទដ្ឋាន បច្ចេកទេស ប្លង់គំរូផ្សេងៗ សំរាប់អនុវត្តភារកិច្ចទាំងឡាយរបស់ជំនាញ ប្រកបដោយជោគជ័យ ។

* <u>ដង្កាប់ តំណាងអោយៈ</u>

+ ការគ្រប់គ្រង ជួសជុល កែឆ្នៃមធ្យោបាយគ្រឿងចក្រ សម្ភារៈជំនាញ និងមនុស្សយ៉ាងម៉ឺងម៉ាត់ មានគុណភាព និងប្រសិទ្ធភាព ។

* <u>កួរស្រូវទុំ តំណាងអោយៈ</u>

+ ភោគផលកសិកម្ម ខឿនសេដ្ឋកិច្ចជាតិ ដែលបានមកពីការអភិវឌ្ឍន៍ប្រទេសជាតិ ពិសេសវិស័យគមនាគមន៍ ។

* <u>ភ្នីអង្គរ តំណាងអោយៈ</u>

+ ខឿនវប្បធម៌ អារ្យធម៌ និងភាពរុងរឿងរបស់អាណាចក្រខ្មែរ ។

+ ការតស៊ូប្រយុទ្ធ យ៉ាងប្ដូរផ្ដាច់ អង់អាចក្លាហាន ដើម្បីការពារអធិបតេយ្យភាព បូរណភាពទឹកដី វប្បធម៌ប្រពៃណី និងសេចក្ដីថ្លៃថ្នូរ របស់ប្រជាពលរដ្ឋ និងមាតុភូមិកម្ពុជា ។

* <u>ខឿនទ្រព្រះពិស្ណុការមានអក្សរវិស្វកម្ម តំណាងអោយៈ</u>

+ គ្រឹះដ៏រឹងមាំ និងការអភិវឌ្ឍន៍របស់កងវិស្វកម្ម លើគ្រប់វិស័យ ។

+ ការសាមគ្គីភាព ឯកភាពផ្ទៃក្នុងជាធ្លុងមួយ ឆន្ទៈ និងគោលជំហរដ៏រឹងមាំ របស់កងវិស្វកម្ម ... ។

[illegible]

[illegible]



- សំរាប់កាក់លើឯកសណ្ឋានប្រយុទ្ធ ដោយដេរភ្ជាប់លើកអាវខាងស្តាំ

